ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩

# សេចក្តីប្រកាសព័ត៌មាន

## ការបំភិតបំភ័យលើតំណាងរាស្ត្រមកពីគណបក្សប្រឆាំង: ការគំរាមកំហែងដកអភ័យឯកសិទ្ធិពីលោកស្រី មូ សុខហួរ

អង្គការសង្គមស៊ីវិលកម្ពុជា សូមសំដែងការខកចិត្តចំពោះសេចក្តីរាយការណ៍ព័ត៌មានគំរាមកំហែងដកអភ័យឯកសិទ្ធិសភាពីលោកស្រី មូ សុខហួរ ដែលជាតំណាងរាស្ត្រ។

កាលពីថ្ងៃព្រហស្បតិ៍សប្តាហ៍មុន តំណាងរាស្ត្រមកពីគណបក្សសមរង្ស៊ី លោកស្រី មូ សុខហួរ បានប្រកាសថានឹងប្តឹង សម្តេចនាយករដ្ឋមន្ត្រីអំពីបទបរិហារកេរ្តិ៍ទាក់ទងទៅនឹងការធ្វើអត្ថាធិប្បាយដែលបានថ្លែងជាសាធារណៈនៅខេត្តកំពត កាលពីថ្ងៃទី៤ ខែមេសា កន្លងទៅនេះ។ មួយថ្ងៃបន្ទាប់ពីការប្រកាសនេះ ស្ថានីយ៍ទូរទស្សន៍មួយដែលគាំទ្ររដ្ឋាភិបាលបានដកស្រង់សម្តីរបស់ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីដែលបានមានប្រសាសន៍ថា រដ្ឋាភិបាលនឹងធ្វើការប្តឹងបកទៅលោកស្រី មូ សុខហួរ ហើយតំណាងរាស្ត្រមកពីគណបក្សប្រជាជនកម្ពុជាទាំងអស់គាំទ្រនូវការដកអភ័យឯកសិទ្ធិសភានេះពីលោកស្រី មូ សុខហួរ។

លោក អ៊ូ វីរៈ ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) បានមានប្រសាសន៍ថា "ការគំរាមកំហែងព្យួរអភ័យឯកសិទ្ធិសភារបស់លោកស្រី មូ សុខហួរ ដោយមិនមានភស្តុតាងណាមួយទាក់ទងទៅនឹងបទល្មើសដែលប្រព្រឹត្តដោយលោកស្រីនោះ គឺជាការបង្កការបំភិតបំភ័យចំពោះតំណាងរាស្ត្រមកពីគណបក្សជំទាស់" ហើយ "នេះសបញ្ជាក់ឱ្យឃើញយ៉ាងច្បាស់អំពី បំណងបំបិតសម្លេង និងរំខានលោកស្រីក្នុងការប្រើប្រាស់សិទ្ធិតាមផ្លូវច្បាប់ក្នុងការរកយុត្តិធម៌ពីបទបរិហារកេរ្តិ៍"។

លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក ប្រធានលីកាដូ (LICADHO) បានមានប្រសាសន៍ថា "តំណាងរាស្ត្រមកពីគ្រប់គណបក្សទាំងអស់ ត្រូវតែមានសេរីភាពក្នុងការបំពេញតួនាទី និងតំណាងឱ្យផលប្រយោជន៍របស់ម្ចាស់ឆ្នោត ហើយបញ្ចេញមតិជាសាធារណៈអំពីបញ្ហាសំខាន់ៗ ដោយមិនមានការភ័យខ្លាច ចំពោះការចាប់ខ្លួន ឬឃុំ

ឃាំងដោយបំពានឡើយ" ។ "ការគំរាមកំហែងមកលើលោកស្រី មួ សុខហួរ គឺជាឧទាហរណ៍មួយទៀតនៃការប្រឈមមុខនឹងបរិយាកាសគ្រោះថ្នាក់របស់តំណាងរាស្ត្រមកពីគណបក្សជំទាស់នៅក្នុងប្រទេសកម្ពុជា" ។

លោក យ៉េង វីរៈ នាយកប្រតិបត្តិនៃមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC) បានមានប្រសាសន៍ថា "តំណាងរាស្ត្រគ្រប់រូបមានអភ័យឯកសិទ្ធិសភា ។ ទោះមកពីគណបក្សណាក៏ដោយតំណាងរាស្ត្រទាំងអស់ ត្រូវមានទំនុកចិត្តក្នុងការពិភាក្សាអំពីបញ្ហាស្រួចស្រាវចំពោះសាធារណៈជន ដោយមិនមានការភ័យខ្លាចចំពោះការប្រកាន់ទោសពៃឡើយ ។ ហើយការដកអភ័យឯកសិទ្ធិសភា មិនមែនជាអ្វីដែលអាចធ្វើតាមតែចិត្តនឹកឃើញរបស់មន្ត្រីរដ្ឋាភិបាលឡើយ" ។

មានករណីមួយ ដែលបានកើតឡើងរួចមកហើយទាក់ទងនឹងការដកអភ័យឯកសិទ្ធិសភារបស់តំណាងរាស្ត្រមកពីគណបក្សជំទាស់ ដែលធ្វើឱ្យមានការកាត់ទោសពីបទព្រហ្មទណ្ឌដែលមិនគួរជឿ ដែលក្នុងករណីនេះអភ័យឯកសិទ្ធិសភារបស់តំណាងរាស្ត្រមកពីគណបក្សសមរង្ស៊ី លោក ជាម ចន្នី ត្រូវបានដកហូតនៅក្នុងខែកុម្ភៈឆ្នាំ២០០៥ ហើយបន្ទាប់មកលោកត្រូវបានចាប់ខ្លួន និងកាត់ទោសក្រោមបទល្មើសបង្កើតកងទ័ពឧទ្ទាម។ សវនាការកាត់ទោសលោក ជាម ចន្នី ដោយតុលាការយោធាត្រូវបានមជ្ឈដ្ឋានទូទៅរិះគន់អំពីភាពអយុត្តិធមិ ចំណែកខាងក្រុមអ្នកជំនាញការឯករាជ្យរបស់អង្គការសហប្រជាជាតិក្រោយមកបានរកឃើញថា ការដាក់ពន្ធនាគារ លោក ជាម ចន្នី ធ្វើឡើងដោយរំលោភទាំងទៅលើច្បាប់ជាតិ និងច្បាប់អន្តរជាតិ។ ក្រោយមកលោកត្រូវបានគេដោះលែងឱ្យមានសេរីភាពវិញ បន្ទាប់ពីជាប់នៅក្នុងពន្ធនាគារអស់ រយះពេល ១៨ខែ។

លោក គល់ បញ្ញា ប្រធានគណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធមិនៅកម្ពុជា (COMFREL) បានមានប្រសាសន៍ថា "ប្រសិនបើ អភ័យឯកសិទ្ធិសភារបស់លោកស្រី មួ សុខហួរត្រូវបានដកហូត

នោះ គឺជាការបញ្ជាក់ថា តំណាងរាស្ត្រមកពីគណបក្សជំទាស់មិនមានសេរីភាពក្នុងការបំពេញមុខនាទី ដោយពុំចាំបាច់ភ័យខ្លាច ចំពោះការបំភិតបំភ័យ និងដាក់ទោសពៃឡើយ" ។

លោកស្រី ធីតា ឃឺះ នាយិកាអង្គការ សិលការ (SILAKA) បានមានប្រសាសន៍ថា "ការគំរាមកំហែងទៅលើតំណាងរាស្ត្រ គឺជារឿងគួរឱ្យសោកស្តាយជាខ្លាំង នៅពេលដែលទង្វើនេះធ្វើទៅលើសកម្មជននយោបាយស្ត្រី

មួយរូបក្នុងចំណោមសកម្មជននយោបាយស្ត្រី ដែលមិនមានច្រើននៅក្នុងប្រទេសកម្ពុជាដែលជារឿយៗសម្លេងស្ត្រីត្រូវបានគេគៀបសង្កត់ និងមិនទទួលស្គាល់”។

អង្គការសង្គមស៊ីវិលកម្ពុជា សូមអំពាវនាវចំពោះតុលាការក្រុងភ្នំពេញ សូមមេត្តាធ្វើការប្រកបទៅដោយស្មារតីឯករាជ្យ និងមិនលំអៀង ហើយសូមអំពាវនាវចំពោះតំណាងរាស្ត្រមកពីគ្រប់គណបក្សទាំងអស់ សូមធ្វើការការពារតួនាទីនៃស្ថាប័នសភា និងតំណាងរាស្ត្រ ហើយសូមមេត្តាជៀសវាងដកអភ័យឯកសិទ្ធិសភារបស់តំណាងរាស្ត្រណាក៏ដោយ វៀរលែងតែមានភស្តុតាងបទល្មើសគ្រប់គ្រាន់។

**សេចក្តីប្រកាសព័ត៌មាននេះ គាំទ្រដោយអង្គការសង្គមស៊ីវិលកម្ពុជាខាងក្រោម:**

អង្គការខារាមកម្ពុជា (CARAM)
មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC)
គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL)
អង្គការយេនឌ័រ និង ការអភិវឌ្ឍន៍ដើម្បីកម្ពុជា (GAD/C)
វិទ្យាស្ថានខ្មែរសំរាប់លទ្ធិប្រជាធិបតេយ្យ (KID)
អង្គការជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO)
គណៈកម្មាធិការអព្យាក្រិត និងយុត្តិធម៌ ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅកម្ពុជា (NICFEC)
អង្គការសិលការ (SILAKA)